គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
ឥណទាន ពលរដ្ឋរុងរឿង អិលធីឌី
INTEAN POALROATH RONGROEURNG LTD

Phone: 023 990 237, Fax: 023 950 211,
Email: info@iprmfi.com, Website: www.iprmfi.com
Address: #. 72B, St. 317, Village 06, Sangkat Boeung Kak 02,
Khan Toul Kork, Phnom Penh, Cambodia.

ថ្ងៃពុធ ០៦រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧
ត្រូវនឹងថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៣

# ដំណឹងជ្រើសរើសបុគ្គលិក

**គ្រឹះស្ថាន ឥណទានពលរដ្ឋរុងរឿង អិលធីឌី** ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឯកជន ដែលមានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ដែលបានធ្វើប្រតិបត្តិការមីក្រូហិរញ្ញវត្ថុរយៈពេលប្រមាណជាង ១៦ ឆ្នាំមកហើយ។ ដើម្បីពង្រឹង និងពង្រីកសកម្មភាពប្រតិបត្តិ ការឥណទាន គ្រឹះស្ថានយើងខ្ញុំត្រូវការជ្រើសរើសបុគ្គលិកសម្រាប់បំពេញមុខតំណែងដូចខាងក្រោម៖

| ល.រ | កន្លែងធ្វើការ/សាខា | តំណែង | ចំនួន |
|---|---|---|---|
| ១ | សាខាស្រុកភ្នំស្រួច | មន្ត្រីឥណទាន (Credit Officer) | ០២ នាក់ |

## ភារកិច្ច និងការទទួលខុសត្រូវរបស់មន្ត្រីឥណទាន ( Credit Officer ):

- ធានាអនុវត្តតាមបទបញ្ជាផ្ទៃក្នុង ក្រមសីលធម៌គ្រឹះស្ថាន ក្រមប្រតិបត្តិរបស់សមាគមមីក្រូហរញ្ញវត្ថុកម្ពុជា គោលការណ៍ឥណទាន នីតិវិធីឥណទាន និងគោលការណ៍ណែនាំរបស់គ្រឹះស្ថានផ្សេងៗទៀត។
- ធានាអនុវត្តតាមផែនការប្រតិបត្តិការដែលបានដាក់អោយអនុវត្តដោយគណៈគ្រប់គ្រងក្នុងការបញ្ចេញប្រាក់កម្ចី ថែរក្សាអតិថិជន រក្សាគុណភាពផលប័ត្រឥណទាន និងដោះស្រាយបំណុលយឺតយ៉ាវ ដោយអនុលោមទៅតាម គោលការណ៍ នីតិវិធីឥណទាន ចក្ខុវិស័យ និងបេសកកម្មរបស់គ្រឹះស្ថាន។
- ធានារក្សាទំនាក់ទំនងល្អជាមួយអតិថិជន អាជ្ញាធរមូលដ្ឋាន និងបុគ្គលពាក់ព័ន្ធផ្សេងទៀត ខិតខំបម្រើសេវាកម្មដល់អតិថិជន ទទួលយកនូវព័ត៌មានត្រលប់ សំណូមពរ និងបណ្តឹងតវ៉ា ហើយជួយដោះស្រាយបញ្ហារបស់អតិថិជនអោយបានល្អបំផុត។
- សិក្សាស្វែងយល់ និងគោរពតាមគោលការណ៍ នីតិវិធីទាំងអស់របស់គ្រឹះស្ថាន និងគោលការណ៍ណែនាំ សេចក្តីសម្រេច អនុស្សរណៈ និងឯកសារនៃការសម្រេចផ្ទៃក្នុងផ្សេងៗ។
- ធ្វើការសិក្សាស្រាវជ្រាវតំបន់ប្រតិបត្តិការដែលមានសក្តានុពលក្នុងសាខា ក្រោមការណែនាំពីប្រធានសាខា ឬអ្នកគ្រប់គ្រង មានដូចជា: ចំនួនប្រជាជន ឬគ្រួសារ សកម្មភាពអាជីវកម្ម ផលិតផលកសិកម្ម ប្រព័ន្ធធារាសាស្ត្រ និងការដឹកជញ្ជូន ហេដ្ឋារចនាសម្ព័ន្ធ ចំនួនស្ថាប័នមីក្រូហិរញ្ញវត្ថុ និងព័ត៌មានដែលពាក់ព័ន្ធផ្សេងៗទៀត។

- ផ្សព្វផ្សាយពីផលិតផល និងសេវាកម្មរបស់គ្រឹះស្ថានជូនដល់អតិថិជនដែលមានសក្តានុពល ព្រមទាំងអាជ្ញាធរ និងមនុស្សដែលមានមុខមាត់ក្នុងសហគមន៍។
- ធ្វើការវាយតម្លៃឥណទានអោយបានហ្មត់ចត់និងម៉ឺងម៉ាត់ដែលស្ថិតក្នុងការទទួលខុសត្រូវរបស់ខ្លួន លើការដាក់ពាក្យស្នើសុំ ខ្ចីពីអតិថិជនដែលមានសក្តានុពល រួមទាំងការចុះសិក្សាអតិថិជន ព្រមទាំងចេះពិគ្រោះយោបល់ជាមួយអាជ្ញាធរ អ្នកជិតខាង គណនាលំហូរសាច់ប្រាក់ បំពេញទម្រង់វាយតម្លៃនិងអនុម័តឥណទានដោយផ្អែកលើកត្តា២គឺ៖
    - **5Cs**៖ (អត្តចរិក សមត្ថភាពសង ដើមទុន ទ្រព្យដាក់ធានា លក្ខខណ្ឌ) ។
    - **5Rs**៖ (ចរិតលក្ខណៈមនុស្ស មុខរបរត្រឹមត្រូវមិនខុសច្បាប់ ទំហំឥណទានសមនឹងសមត្ថភាពសង រយៈពេល កម្ចីត្រូវ នឹងមុខរបរ ទីតាំងអាជីវកម្មមានសក្តានុពល) ។ បន្ទាប់មកត្រូវបញ្ជូនឯកសារទាំងនេះទៅអ្នកគ្រប់គ្រងដើម្បី ធ្វើការត្រួតពិនិត្យ។
- តាមដានអតិថិជនដែលជាផលប័ត្ររបស់ខ្លួនអោយបានទៀងទាត់ និងចុះជួបអតិថិជនកំពុងដាក់ស្នើសុំស្ថាប័នដទៃតាមរយៈការជាវរបាយការណ៍ពី CBC និងការចុះធ្វើ កំណត់ចំណាត់ថ្នាក់ឥណទានឡើងវិញនៅពេលណាមានការបង់ សងយឺតយ៉ាវ ឬក្នុងអំឡុងពេល២ខែម្តងដោយផ្តោត លើចំណុចមួយចំនួនរួមមាន៖ គោលបំណងនៃការប្រើប្រាស់ ឥណទាន មុខរបរ/អាជីវកម្ម ទ្រព្យអតិថិជន ទ្រព្យដាក់ធានា បំណុល ស្ថានភាពគ្រួសារ ស្ថានភាពបំណុល សុខភាព អតិថិជនឬគ្រួសារដើម្បីធ្វើការសិក្សា កំណត់ហានិភ័យឥណទាន និងបញ្ហាដោះស្រាយបំណុលយឺតយ៉ាវ (ឥណទាន មិនដំណើរការ និងលុបចេញពីបញ្ជី)។ ជាពិសេសពិនិត្យមើលការចម្រើនលូតលាស់នៃអាជីវកម្មរបស់អតិថិជន និងប្រាប់ឲ្យប្រធានសាខាបានដឹងជាមុនប្រសិនបើអតិថិជនដែលដល់កាលកំណត់សង ហើយមានការសង្ស័យថានឹងអាចបង់សងយឺតយ៉ាវ។ មន្ត្រីឥណទានក៏អាចជួយធ្វើផែនការហិរញ្ញវត្ថុជូនដល់អតិថិជនរហូតដល់អតិថិជនត្រូវបានសង ឥណទានចប់សព្វគ្រប់។
- រាល់ការស្នើសុំកម្ចីឡើងវិញត្រូវពិនិត្យមើលនូវស្ថានភាពអតិថិជន ដូចជាមុខរបរ ទ្រព្យដាក់ធានា និងបំណុលរបស់គាត់ បើទោះជាមានលក្ខណៈល្អប្រសើរក៏ដោយ។
- ក្នុងករណីអតិថិជនដែលជាផលប័ត្ររបស់ខ្លួនមិនបានសងតាមកាលកំណត់មកគ្រឹះស្ថាន ត្រូវតាមដានពីស្ថានភាព របស់ពួកគាត់ឲ្យបានជាប់លាប់ ព្យាយាមធ្វើការដោះស្រាយដោយចូលរួមជាមួយប្រធានសាខាឬមន្ត្រីដោះស្រាយបំណុលជាមួយអតិថិជន ហើយក៏អាចធ្វើការទាក់ទងជាមួយអាជ្ញាធរ មន្ត្រីមានសមត្ថកិច្ចក្នុងតំបន់ មេធាវី និងតុលាការ។
- មន្ត្រីឥណទានត្រូវប្រកាន់ខ្ជាប់នូវទំនាក់ទំនងល្អជាមួយអតិថិជនបច្ចុប្បន្ន ឬអតិថិជនដែលមានសក្តានុពល និងអាជ្ញា ធរ ឬអ្នកមានមុខមាត់នៅក្នុងសហគមន៍ ព្រមទាំងដៃគូរពាក់ព័ន្ធដទៃទៀត។
- មន្ត្រីឥណទានក៏ត្រូវប្រកាន់ខ្ជាប់នៅទំនាក់ទំនងល្អជាមួយបុគ្គលិកសាខាដទៃទៀត និងបុគ្គលិកនៅស្នាក់ការកណ្តាល ក្នុងការសំរបសំរួលការងារសាខា ប្រសិនបើមានតម្រូវការពីអ្នកគ្រប់គ្រង។

Phone: 023 990 237, Fax: 023 950 211,
Email: info@iprmfi.com, Website: www.iprmfi.com
Address: #. 72B, St. 317, Village 06, Sangkat Boeung Kak 02,
Khan Toul Kork, Phnom Penh, Cambodia.

- ធ្វើការសិក្សាស្រាវជ្រាវព័ត៌មានទីផ្សារតាមការណែនាំរបស់ប្រធានសាខា និងនាយកដ្ឋានប្រតិបត្តិការ ធានារកអោយឃើញនូវតម្រូវការទីផ្សារពិតប្រាកដ ព័ត៌មានរបស់គូរប្រគួតប្រជែងដែលមានដូចជា តម្លៃការប្រាក់ កម្រៃឥណទាន រយៈពេល លក្ខខ័ណ្ឌនៃការបង់សងប្រាក់ លក្ខខ័ណ្ឌនៃការធ្វើបុនហិរញ្ញប្បទាន និងយុទ្ធសាស្ត្រទីផ្សារផ្សេងៗ។
- មន្ត្រីឥណទានត្រូវសហការអនុវត្តយន្តការឆ្លើយតបចំពោះពត៌មានត្រឡប់របស់អតិថិជន (Client Feedback Mechanism) ដែលក្នុងនោះរួមមានការណែនាំអតិថិជនឲ្យស្គាល់ និងចេះប្រើប្រាស់យន្តការឆ្លើយតបចំពោះពត៌មានត្រឡប់របស់ខ្លួន ការប្រមូល និងការឆ្លើយតបចំពោះពត៌មានត្រឡប់និងបណ្ដឹងតវ៉ារបស់អតិថិជន។ (តួនាទីនិងភារកិច្ចលម្អិតដូចមានចែងនៅក្នុងយន្តការឆ្លើយតបចំពោះពត៌មានត្រឡប់របស់អតិថិជន)។ ទទួលយកការឲ្យយោបល់ពីការពេញចិត្តរបស់អតិថិជនជាមួយគ្រឹះស្ថាន ហើយធ្វើការស្នើសុំដើម្បីធ្វើការកែលម្អសេវាកម្មរបស់គ្រឹះស្ថានឲ្យកាន់តែល្អប្រសើរជាងមុន។

**លក្ខខណ្ឌនៃការជ្រើសរើសរបស់មន្ត្រីឥណទាន (Credit Officer):**

- មានបរិញ្ញាបត្រគ្រប់គ្រងពាណិជ្ជកម្ម (ឬកំពុងរៀនឆ្នាំទី ៤)។
- មានបទពិសោធន៍ជាមន្ត្រីឥណទានចាប់ពី ៣ខែ ឡើងទៅ។
- មានចរិកស្មោះត្រង់ រស់រាយរាក់ទាក់ តស៊ូព្យាយាម និងមានសីលធម៌។
- ចេះភាសារអង់គ្លេស អាចស្តាប់ និងអានបាន។
- មានចំណេះដឹងកុំព្យូទ័រ Microsoft Office, E-mail, Internet។

**អត្ថប្រយោជន៍ដែលទទួលបាន៖**

គ្រឹះស្ថានផ្តល់ជូនបុគ្គលិកនូវអត្ថប្រយោជន៍ជាច្រើនដូចជា៖

- ប្រាក់បៀវត្សគោលប្រចាំខែ សមរម្យស្របតាមសមត្ថភាព បទពិសោធន៍ការងារ និងកំរិតវប្បធម៌
- ប្រាក់រង្វាន់ប្រចាំខែដោយផ្អែកលើលទ្ធផលការងារដែលសម្រេចបាន
- ប្រាក់រង្វាន់លើកទឹកចិត្តប្រចាំឆ្នាំផ្អែកលើប្រាក់ចំណេញរបស់គ្រឹះស្ថាន
- ប្រាក់លើកទឹកចិត្តពេលចូលឆ្នាំខ្មែរ និងពេលភ្ជុំបិណ្ឌ
- ប្រាក់ឧបត្ថម្ភមាតុភាព (សម្រាប់បុគ្គលិកជាស្ត្រី)
- ការធានារ៉ាប់រងសុខភាពនិងគ្រោះថ្នាក់ការងារពីបេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស)
- ច្បាប់ឈប់សម្រាកប្រចាំឆ្នាំ ១៨ ថ្ងៃ ឈប់សម្រាកមានជំងឺ ១០ ថ្ងៃ
- ឧបត្ថម្ភឯកសណ្ឋានការងារជារៀងរាល់ឆ្នាំ
- និងអត្ថប្រយោជន៍ដទៃផ្សេងទៀតតាមគោលការណ៍ធនធានមនុស្សរបស់គ្រឹះស្ថាន។

**របៀបនៃការដាក់ពាក្យ**

បេក្ខជនមានចំណាប់អារម្មណ៍សូមផ្ញើប្រវត្តិរូបសង្ខេប **(CV)** លិខិតអម **(Cover Letter)** មកកាន់គ្រប់ស្នាក់ការសាខាគ្រឹះស្ថាន **ឥណទានពលរដ្ឋរុងរឿង អិលធីឌី** ដែលមានទីតាំងស្ថិតនៅជិតបំផុត រឺផ្ញើមកកាន់នាយកដ្ឋាន

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
ឥណទាន ពលរដ្ឋរុងរឿង អិលធីឌី
INTEAN POALROATH RONGROEURNG LTD
Phone: 023 990 237, Fax: 023 950 211,
Email: info@iprmfi.com, Website: www.iprmfi.com
Address: #. 72B, St. 317, Village 06, Sangkat Boeung Kak 02,
Khan Toul Kork, Phnom Penh, Cambodia.

ធនធានមនុស្សការិយាល័យកណ្តាលដែលមានអាសយដ្ឋានផ្ទះលេខ72B ផ្លូវលេខ 317 ភូមិ០៦ សង្កាត់បឹងកក់ ០២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឬតាមរយៈអ៊ីម៉ែល hof@iprmfi.com or job@iprmfi.com។ សូមចូលទៅកាន់គេហទំព័រ www.iprmfi.com ឬទាក់ទងលេខទូរស័ព្ទ (Telegram) 010 520 000 សម្រាប់ព័ត៌មានបន្ថែម។

**បញ្ជាក់៖**

- **គ្រឹះស្ថាននឹងឈប់ទទួលពាក្យនៅពេលដែលបុគ្គលិកត្រូវបានជ្រើសរើសបានគ្រប់ចំនួន (អ្នកដាក់ពាក្យមុនមានអាទិភាពក្នុងការជ្រើសរើសអោយចូលធ្វើការមុន)។**
- មានតែបេក្ខជនដែលមានគុណសម្បត្តិគ្រប់គ្រាន់នឹងត្រូវបានទំនាក់ទំនងតាមលេខទូរស័ព្ទ។
- រាល់ឯកសារដាក់ពាក្យមកគ្រឹះស្ថាន នឹងមិនត្រូវបានប្រគល់អោយវិញឡើយ។
- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ឥណទានពលរដ្ឋរុងរឿង អិលធីឌី** ប្រកាន់ខ្ជាប់នូវតម្លាភាព អព្យាក្រិត និងមិនលម្អៀងហើយមិនប្រកាន់ពូជសាសន៍ ព័ណ៌សម្បុរ សាសនា នយោបាយ ភេទ ពិការភាព និងស្ថានភាពគ្រួសារឡើយ។